**សំណួរ**

**អ្វីទៅជាសិទ្ធិដាច់ខាត?**

**ចម្លើយ**

សិទ្ធិមនុស្ស បែកចេញជាសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម សិទ្ធិកុមារ (មាត្រា៣១ ដល់ មាត្រា ៥០ នៃ ជំពូកទី ៣ នៃ ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ មានចែងអំពីសិទ្ធិទាំងនេះ)។ ប្រសិនបើគេនិយាយ អំពី ចរិតលក្ខណៈនៃសិទ្ធិ មានសិទ្ធិដាច់ខាត ឬមិនដាច់ខាត។ តើអ្វីទៅជាសិទ្ធិដាច់ខាត?

សិទ្ធិដាច់ខាត ជាសិទ្ធិដែលបុគ្គល អាចប្រាស្រ័យបានក្នុងគ្រប់កាលៈទេសៈ ទោះបីក្នុងពេលគ្រោះ អាសន្នជាសាធារណៈ ដូចជាសង្គ្រាមក្តី។ ម្ចាស់កាតព្វកិច្ច (ជាទូទៅរដ្ឋ) ត្រូវគោរព និងអនុវត្ត ដោយគ្មាន ការផ្អាកឡើយ។ ប្រសិនបើផ្អាកអនុវត្ត ឬមិនគោរព មិនអាចយកអ្វីមកសំអាងដោះសារ ដើម្បីរួចផុតពីការ ទទួលខុសត្រូវ ចំពោះការបំពានសិទ្ធិប្រភេទនេះឡើយ។ មាត្រា ៧ នៃកតិកាសញ្ញាស្តីពីសិទ្ធិស៊ីវិល និង នយោបាយ ដែលកម្ពុជា ជាភាគីតាំងពីឆ្នាំ ១៩៩២ ចែងហាមឃាត់អំពើទារុណកម្ម។ អានខ្លឹមសារនៃ មាត្រានេះ ជាមួយនឹងមាត្រា ៤ នៃកតិកាសញ្ញាដដែល ដែលចែងថា *"មិនមានការផ្អាកអនុវត្តសិទ្ធិក្នុងមាត្រា ៦, ៧,៨ (កថាខណ្ឌទី ១ និង២), ១១, ១៥, ១៦ និង ១៨ ត្រូវបានអនុញ្ញាតទេ"* សិទ្ធិរួចផុតពីអំពើ ទារុណកម្ម ទាញចេញពីការហាមឃាត់អំពើទារុណកម្ម *ជាសិទ្ធិដាច់ខាត។* ក្នុងន័យនេះ អាជ្ញាធរមិនអាច ធ្វើអំពើទារុណកម្ម លើជនណាមួយ ដើម្បីយកចម្លើយសារភាព ក្នុងអំឡុងពេលបង្ក្រាប នាពេលមានគ្រោះ អាសន្នជាសាធារណៈទេ។

ការចាត់ជាសិទ្ធិដាច់ខាត ទំនងដោយសារតម្លៃជាចម្បងក្នុងការហាមឃាត់ ឬបង្ការអំពើទារុណ កម្ម។ ស្របគ្នានេះ ការហាមឃាត់អំពើទារុណកម្ម បានក្លាយជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ (Customary International Law), ជាវិធានខ្ពស់បំផុត *(Jus Cogens)* និងបង្កើតចេញជាកាតព្វកិច្ចចងដល់រដ្ឋទាំងអស់ *(Erga Omnes Obligation)*។ សូមមើលសំណួរចម្លើយ ពាក់ព័ន្ធពាក្យគន្លឹះទាំងនេះ ក្នុងអត្ថបទផ្សេង ទៀត។

**Further Readings**: Natasa Mavronicola, *what is an absolute right? Deciphering Absoluteness in the context of Article 3 of the European Convention on Human Rights*, Human Rights Law Review 12:4(2012), 723-758; Miachael K. Addo and Nicholas Grief, *Does Article 3 of the European Convention on Human Rights Enshrine Absolute rights*? European Journal of International Law 9 (1998), 510-52; The *Absolute and Comprehensive Prohibition of Torture and other Cruel, Inhuman or Degrading Treatment or Punishment Swedish Forum on Human Rights*, Stockholm, 16-17 November 2005, https://www.apt.ch/content/files_res/TortureProhibition_SFHR.pdf